ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
MINISTRY OF ECONOMY AND FINANCE
FAX / PHONE : ( 855 ) 23 27798

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

លេខ ៖ ៣៦៣ សហវ-លស-ប្រក

# ប្រកាស

## ស្តីពី

## ការចុះឈ្មោះក្នុងបញ្ជីអ្នកទទួលការសាងសង់

**********

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃ ព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះបាទសម្តេចព្រះនរោត្តមសីហនុវរ្ម័ន ព្រះមហាក្សត្រ នៃ ព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការតែងតាំង រាជរដ្ឋាភិបាល
- បានឃើញច្បាប់ស្តីពីការរៀបចំ និង ប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ចុះថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤
- បានឃើញអនុក្រឹត្យលេខ ៦០ អនក្រ បក ចុះថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ ១៩៩៥ ស្តីពីការគ្រប់គ្រងលទ្ធកម្មសាធារណៈ ។
- បានឃើញប្រកាសលេខ ៣១៩ សហវ-ម-ប្រក ចុះថ្ងៃទី៣១ ខែ សីហា ឆ្នាំ១៩៩៥ ស្តីពីការអនុវត្តន៍ វិធាន និង បទបញ្ញត្តិ ក្នុងការគ្រប់គ្រង លទ្ធកម្មសាធារណៈ ។
- បានឃើញការចាំបាច់របស់ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

## សំរេច

ប្រការ១ - ដើម្បីមានសិទ្ធិ ចូលរួមធ្វើការដេញថ្លៃ លើរាល់គំរោងការងារសាងសង់សាធារណៈ គ្រប់ប្រភេទនៅតាមបណ្តា ក្រសួង ស្ថាប័ន និង ខេត្ត ក្រុង ក្រុមហ៊ុនសាងសង់ នៅក្នុងព្រះរាជាណាចក្រកម្ពុជា ដែលមាន នីតិសម្បទាត្រឹមត្រូវ ត្រូវតែបានមកចុះឈ្មោះក្នុងបញ្ជី អ្នកទទួលការសាងសង់ នៅ នាយកដ្ឋាន លទ្ធកម្ម

សាធារណៈ នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ដើម្បីបញ្ជាក់ពីប្រភេទរបស់ក្រុមហ៊ុន និង ចំណាត់ថ្នាក់នៃគំរោងដែលក្រុមហ៊ុនអាចធ្វើបាន ។

ប្រការ២ - គោលការណ៍ណែនាំ ស្តីពីការបែងចែកតាមប្រភេទ និងការចុះបញ្ជីអ្នកទទួលការសាងសង់ ត្រូវកំណត់ឡើងដោយនាយកដ្ឋានលទ្ធកម្មសាធារណៈ ។

ប្រការ៣ - ប្រកាសនេះ ចូលជាធរមានចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ , ថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ១៩៩៥

ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

កេង វ៉ាន់សាក់

កន្លែងទទួល ៖

- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
- គ្រប់ក្រសួង-រដ្ឋលេខាធិការដ្ឋាន
- គ្រប់ខេត្ត-ក្រុង
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ: ០០៥ សហវ.លសធ

រាជធានីភ្នំពេញ,ថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៦

# សេចក្តីជូនដំណឹង

- យោងអនុក្រឹត្យរបស់រាជរដ្ឋាភិបាលលេខ ៦០អនក្រ.បក ចុះថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ១៩៩៥ ស្តីពីការគ្រប់គ្រងលទ្ធកម្មសាធារណៈ
- យោងប្រកាសរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ លេខ ៣៦៣ សហវ.លសធ ចុះថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥ ស្តីពីការចុះឈ្មោះក្នុងបញ្ជីអ្នកទទួលការសាងសង់ ។

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុមានកិត្តិយសជំរាបជូនគ្រប់ក្រុមហ៊ុនសាងសង់ទាំងអស់ក្នុងព្រះរាជាណាចក្រកម្ពុជា ជ្រាបថា ចាប់ពីថ្ងៃទី ០១ ខែ មករា ឆ្នាំ ១៩៩៧ តទៅក្រសួងនឹងមិនអនុញ្ញាតអោយក្រុមហ៊ុនទាំងឡាយណាដែលគ្មានវិញ្ញាបនប័ត្របញ្ជាក់ការចុះឈ្មោះក្នុងបញ្ជីអ្នកទទួលការសាងសង់ចូលរួមក្នុងការដេញថ្លៃលើគំរោងការងារសាងសង់សាធារណៈគ្រប់ប្រភេទនៅតាមបណ្តា ក្រសួង ស្ថាប័ន និង ខេត្ត-ក្រុងនានា ឡើយ ។

អាស្រ័យហេតុនេះសូមលោក លោកស្រីជានាយកក្រុមហ៊ុនសំណង់ទាំងអស់ដែលមិនទាន់មានវិញ្ញាបនប័ត្របញ្ជាក់ការចុះឈ្មោះក្នុងបញ្ជីអ្នកទទួលការសាងសង់មេត្តាមកទំនាក់ទំនងជាមួយនាយកដ្ឋានលទ្ធកម្មសាធារណៈដើម្បីសុំចុះឈ្មោះក្នុងបញ្ជីអ្នកទទួលការសាងសង់ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

សូមអស់លោក លោកស្រីជានាយកក្រុមហ៊ុនសាងសង់ទាំងអស់មេត្តាជ្រាប និង ចាប់អារម្មណ៍ខ្ពស់លើការងារនេះ។

ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

[signature]

គាត ឈន់

ចម្លងជូន :
- គ្រប់ក្រសួងស្ថាប័ន
- គ្រប់ខេត្ត-ក្រុង
- ខុទ្ទកាល័យទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- ឯកសារ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# គោលការណ៍ណែនាំ ស្តីពីការបែងចែក តាមប្រភេទ និង ការចុះបញ្ជីរបស់អ្នកទទួលការ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

វិច្ឆិកា ១៩៩៩

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
នាយកដ្ឋានលទ្ធកម្មសាធារណៈ
លេខ : ០២ ល សា

# គោលការណ៍ណែនាំ ស្តីពីការបែងចែក តាមប្រភេទ និង ការចុះបញ្ជីរបស់អ្នកទទួលការ

( GUIDELINES FOR CATEGORIZATION AND REGISTRATION OF CONTRACTORS )

***********

① យោងតាមអនុក្រឹត្យលេខ ៦០ អនក្រ បក ចុះថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ១៩៩៥ ស្តីពីការគ្រប់គ្រងលទ្ធកម្មសាធារណៈ និង យោងតាមប្រកាសលេខ ៣១៩ សហវ-ម-ប្រក ចុះថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ១៩៩៥ ស្តីពីការអនុវត្តន៍ វិធាននិងបទបញ្ញត្តិ ស្តីពីការគ្រប់គ្រងលទ្ធកម្មសាធារណៈ និង ប្រកាស លេខ ៣៦៣ សហវ លសប្រក ខែ វិច្ឆិកា ឆ្នាំ ១៩៩៥ ស្តីពីការចុះឈ្មោះក្នុងបញ្ជី អ្នកទទួលការសាងសង់ នាយកដ្ឋានលទ្ធកម្មសាធារណៈកំណត់នូវគោលការណ៍ណែនាំ ស្តីពីការបែងចែក តាមប្រភេទ និងការចុះបញ្ជីរបស់អ្នកទទួលការដូចខាងក្រោម :

## ១-គំណុតទូទៅ

ការចុះបញ្ជី និងការបែងចែកតាមប្រភេទអ្នកទទួលការសាងសង់ដោយនាយកដ្ឋានលទ្ធកម្មសាធារណៈធ្វើឡើងដើម្បីប្រមូលផ្តុំ និង សំរួលដល់កិច្ចតម្រូវការចុះបញ្ជីឆ្លងតាមគោលការណ៍ណែនាំ និង លក្ខណៈវិនិច្ឆ័យតែមួយ ។កិច្ចការនេះអាចផ្តល់នូវលទ្ធភាពទទួលពត៏មានចុងក្រោយយ៉ាងទាន់ចិត្ត ពីអ្នកទទួលការ និង ដើម្បីជៀសវាងនូវភាពមិនប្រក្រតីដែលទាក់ទង ទៅនឹងការចុះបញ្ជីដែលមានលក្ខណៈពិសេស ច្រើនដង ឬ មានភាពមិនទៀងទាត់ ។ គោលការណ៍ណែនាំ លក្ខណៈវិនិច្ឆ័យ និង នីតិវិធី ស្តីពីការចុះបញ្ជី និងការបែងចែកតាមប្រភេទអ្នកទទួលការសាងសង់នេះ ត្រូវអនុវត្តដោយក្រសួងស្ថាប័ន និង ខេត្តក្រុងលើរាល់វិស័យសាធារណៈ ។

## ២-និយមន័យនៃពាក្យ

### ក- តំរោងហេដ្ឋារចនាសម្ព័ន្ធ

គឺសំដៅលើការសាងសង់ ការកែលំអ ឬ ការស្តារឡើងវិញ នូវផ្លូវថ្នល់ និង ស្ពាន ព្រលានយន្តហោះ ផ្លូវរថភ្លើង កំពង់ផែ ប្រពន្ធ័គ្រប់គ្រងទឹកជំនន់ និង ប្រឡាយទឹក ការផ្គត់ផ្គង់ទឹក

ស្ពានិង ប្រពន្ធ័លូទឹកស្អុយសំរាម ឬ កាកសំណល់ ប្រព័ន្ធធារាសាស្ត្រ ទំនប់ទឹក សំណង់ទូរគមនាគមន៍ ការជីកដីឬ ចាក់បំពេញរោងចក្រផលិតអគ្គីសនី និងគំរោងសំណង់ផ្សេងៗទៀត ដែលទាក់ទងនឹងវិស័យខាងលើដែលរួមគ្នាទាំងអស់បង្កើតបានជាផ្នែកមួយ នៃកម្មវិធីហេដ្ឋារចនាសម្ព័ន្ធ របស់រដ្ឋាភិបាល ។

ខ- <u>ចំណាត់ថ្នាក់</u>

គឺសំដៅការចាត់ចូលជំនាញណាខ្លះក្នុងគំរោងហេដ្ឋារចនាសម្ព័ន្ធដូចជា ផ្លូវថ្នល់ និង ស្ពានព្រលានយន្តហោះ សំណង់អាគារជាដើម (សូមអានឧបសម្ព័ន្ធ ទី ១ ដែលមានបរិយាយពន្យល់) ។

គ- <u>ប្រភេទ</u>

គឺសំដៅទៅលើការកំណត់លក្ខណៈសម្បត្តិរបស់អ្នកទទួលការ ថា តូច មធ្យម ឬ ធំ ។

ឃ- <u>អ្នកទទួលការ</u>

គឺសំដៅលើបុគ្គល ឬ ជាក្រុមហ៊ុនដែលអនុវត្តការសាងសង់ ដែលជួលដោយរដ្ឋាភិបាល ។

ង- <u>ការសាងសង់</u>

គឺសំដៅលើការងារដែលអ្នកទទួលការត្រូវធ្វើហើយប្រគល់ជូនទៅរដ្ឋាភិបាល ។

ច- <u>កំណត់ត្រាប្រវត្តិការងារ</u>

គឺសំដៅលើតំលៃសរុបនៃការងារ ដែលបានធ្វើក្នុងរយៈ បី ឆ្នាំ ចុងក្រោយ ឬ តំលៃកិច្ចសន្យាតែមួយដែលធំជាងគេបង្អស់ដែលធ្វើឡើង ដោយអ្នកទទួលការ ក្នុងរយៈពេលដូចគ្នា ។

ឆ- <u>វិញ្ញាបនប័ត្របញ្ជាក់ការចុះបញ្ជី</u>

គឺសំដៅលើការប្រកាសពីការចុះបញ្ជី ដែលចេញដោយនាយកដ្ឋាន លទ្ធកម្មសាធារណៈ និងដែលមានតំលៃរយៈពេល ២ ឆ្នាំ ។ ឯកសារនេះ បញ្ជាក់ពីប្រភេទនៃអ្នកទទួលការ និងចំណាត់ថ្នាក់នៃគំរោងការដែលអ្នកទទួលការអាចធ្វើបាន ។

## ៣- <u>បែបបទនៃការចុះបញ្ជី</u>

ក- <u>ចំណុចទូទៅ</u>

" អ្នកទទួលការ " ត្រូវតែបែងចែកតាមប្រភេទ និង ចុះបញ្ជីនៅក្នុងប្រភេទណាមួយក្នុង ចំណោមប្រភេទទាំងបី ដូចជា តូច មធ្យម ធំ ។

គំរោងហេដ្ឋារចនាសម្ព័ន្ធ ត្រូវចាត់ថ្នាក់ជា ១០ថ្នាក់ ។ ជាទូទៅឈ្មោះថ្នាក់ នីមួយៗគ្របដណ្តប់លើ ផ្នែកនៃសំណង់ដែលត្រូវធ្វើឡើងតាមកម្មវិធី ហេដ្ឋារចនាសម្ព័ន្ធរបស់រដ្ឋាភិបាល ។ ការរៀបរាប់អំពីឈ្មោះរបស់ថ្នាក់នីមួយៗ គឺមានពន្យល់នៅក្នុងឧបសម្ព័ន្ធទី១ ។

## ខ- ចំណាត់ថ្នាក់នៃគំរោង

ការសាងសង់ទាំងឡាយ ទោះជាសំណង់ថ្មី ឬ ការកែលំអ ឬការស្តារឡើងវិញដែលធ្វើឡើងដោយក្រសួង ស្ថាប័ន ខេត្ត ក្រុង និង សហគ្រាសសាធារណៈ ជារួមអាចចែកជាថ្នាក់នៃគំរោងដូចតទៅ :

| លេខសំគាល់ | ឈ្មោះថ្នាក់ |
|---|---|
| W1 | ផ្លូវថ្នល់ និង ស្ពាន |
| W2 | ព្រលានយន្តហោះ |
| W3 | សំណង់អគារ |
| W4 | ប្រពន្ធ័ធារាសាស្ត្រ ប្រពន្ធ័បង្ហូរទឹកនិងប្រពន្ធ័គ្រប់គ្រងទឹកជំនន់ |
| W5 | ផ្លូវរថភ្លើង |
| W6 | កំពង់ផែ |
| W7 | ការផ្គត់ផ្គង់ទឹកស្អាត ប្រពន្ធ័លូទឹកស្អុយ |
| W8 | សំណង់ទូរគមនាគមន៍ |
| W9 | ការចាក់ដី បុកគ្រឹះ |
| W10 | ថាមពល |

( ឈ្មោះថ្នាក់នេះមានបរិយាយពន្យល់អត្ថន័យលំអិតនៅក្នុងឧបសម្ព័ន្ធទី១)។

## គ- ប្រភេទអ្នកទទួលការ

អ្នកទទួលការអាចចែកជាប្រភេទផ្សេងៗ ទៅតាមសមត្ថភាពបច្ចេកទេស និង ហិរញ្ញវត្ថុ ព្រមទាំងតាមកំណត់ត្រាប្រវត្តិការងារផងដែរ ។ ការបែងចែកនេះ ផ្អែកលើសមត្ថភាពនៃការចេញថ្លៃទៅតាមតំលៃនៃកិច្ចសន្យា ។ ផ្អែកតាមសភាពការណ៍បច្ចុប្បន្ន ការបែងចែកអ្នកទទួលការសាងសង់នៅក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវបានកំណត់ឡើង ជាបីប្រភេទដូចតទៅ :

| ប្រភេទអ្នកទទួលការ | កំរិតតំលៃនៃកិច្ចសន្យា |
|---|---|
| ប្រភេទតូច | មិនលើសពី ១២៥ លានរៀល |
| ប្រភេទមធ្យម | លើសពី ១២៥ លានរៀល ដល់ ៥០០ លានរៀល |
| ប្រភេទធំ | លើសពី ៥០០ លានរៀល |

## ឃ- គណៈកម្មាធិការបែងចែកតាមប្រភេទនៃអ្នកទទួលការ

នៅក្នុងនាយកដ្ឋានលទ្ធកម្មសាធារណៈ ត្រូវបង្កើតឡើងនូវគណៈកម្មាធិការបែងចែកតាមប្រភេទនៃអ្នកទទួលការដែលមានសមាសភាពដូចតទៅ :

| | |
|---|---|
| អនុប្រធាននាយកដ្ឋានលទ្ធកម្មសាធារណៈ | ជាប្រធាន |
| តំណាងក្រសួងសាធារណៈការ និង ដឹកជញ្ជូន | ជាសមាជិក |
| តំណាងឧស្សាហកម្មសំណង់ក្នុងស្រុក | ជាសមាជិក |

គណៈកម្មាធិការបែងចែកតាមប្រភេទនៃអ្នកទទួលការត្រួតពិនិត្យលើលក្ខណៈសម្បត្តិរបស់អ្នកទទួលការដើម្បីបញ្ជាក់ពីសមត្ថភាពការងាររបស់គេ យោងតាមលក្ខណៈវិនិច្ឆ័យដែលបានចែងក្នុងការទទួលយកនូវគំរោងដែលមានទំហំ និង បែបផ្សេងៗគ្នាដោយពុំចាំបាច់គិតពីកិច្ចសន្យាពិសេសណាមួយឡើយ ។

គណៈកម្មាធិការបែងចែកតាមប្រភេទនៃអ្នកទទួលការ មានសិទ្ធិបន្ថែម លប់ កែប្រែ ឬ ផ្លាស់ប្តូរឈ្មោះ ចំណាត់ថ្នាក់ នៃគំរោងការ ព្រមទាំង ប្រភេទអ្នកទទួលការនៅពេលដែលយល់ថាចាំបាច់ត្រូវតែធ្វើដើម្បីអោយកិច្ចការនោះកាន់តែមានដំណើរការល្អ និង ស្របតាមល័ក្ខខ័ណ្ឌដែលបានចែង។

ដើម្បីជំនួយការដល់ គណៈកម្មាធិការបែងចែកតាមប្រភេទនៃអ្នកទទួលការក្រុមការងារបច្ចេកទេសមួយនឹងត្រូវបង្កើតឡើង ក្នុងនាយកដ្ឋានលទ្ធកម្មសាធារណៈ ដែលចូលរួមដោយ វិស្វករ អ្នកច្បាប់ គណនេយ្យករ និង អ្នកឯកទេសផ្សេងៗទៀត ។ ក្រុមការងារបច្ចេកទេសនេះ ត្រូវមានភារកិច្ចវិភាគ និង ធ្វើការផ្ទៀងផ្ទាត់ នូវបណ្តាព័ត៌មាន និង ឯកសារទាំងឡាយដែលទទួលបានពីអ្នកទទួលការ ព្រមទាំងធ្វើការពិនិត្យដោយផ្ទាល់លើគំរោងការទាំងឡាយ ដែលធ្វើឡើងដោយអ្នកទទួលការ និង ដែលបានចុះបញ្ជីរួចហើយ ។

## ង - សុពលភាពនៃវិញ្ញាបនប័ត្របញ្ជាក់ពីការចុះបញ្ជី

អ្នកទទួលការដែលចុះបញ្ជី យ៉ាងត្រឹមត្រូវនៅនាយកដ្ឋានលទ្ធកម្មសាធារណៈ ត្រូវបានទទួលវិញ្ញាបនប័ត្របញ្ជាក់ពីការចុះបញ្ជីដែលមានសុពលភាពក្នុងរយៈពេល២ ឆ្នាំ គិតចាប់ពីថ្ងៃចេញវិញ្ញាបនប័ត្រនោះ ។ ក្នុងរយៈពេលសុពលភាពនៃវិញ្ញាបនប័ត្របញ្ជាក់ ពីការចុះបញ្ជីនោះអ្នកទទួលការអាចលើកឡើងនូវសំណូមពរតាមពាក្យសុំដើម្បីតំឡើងឋានៈប្រភេទរបស់ខ្លួនឬបន្ថែមឈ្មោះចំណាត់ថ្នាក់ នៃគំរោងការ ។

អ្នកទទួលការត្រូវសុំបន្តជាថ្មីទៀត នូវរាល់សុពលភាពនៃវិញ្ញាបនប័ត្របញ្ជាក់ពីការចុះបញ្ជី ក្នុងរយៈពេល ៣០ ថ្ងៃ មុនអស់សុពលភាព ។

## ច - ការត្រួតពិនិត្យលើសមត្ថភាពរបស់អ្នកទទួលការដែលបានចុះបញ្ជីរួចហើយ

នាយកដ្ឋានលទ្ធកម្មសាធារណៈ ត្រូវត្រួតពិនិត្យលើសមត្ថភាពរបស់អ្នកម៉ូវេការ តាមប្រភេទ និងចំណាត់ថ្នាក់បច្ចុប្បន្ន និងត្រូវចាត់វិធានការសមស្រប " ដូចជាបន្ថយឋានៈប្រភេទ ឬ លប់ចោលនូវចំណាត់ថ្នាក់ណាមួយ " ប្រសិនបើ អ្នកទទួលការមិនបានបំពេញល័ក្ខខ័ណ្ឌអប្បបរិមាដែលបានកំណត់ក្នុងការចាត់ប្រភេទ និង ចំណាត់ថ្នាក់ទាំងនោះ នាពេលណាមួយក្នុងរយៈសុពលភាព

នៃវិញ្ញាបនប័ត្រស្ដីពីការចុះបញ្ជី ។

ឆ- <u>លក្ខណៈសម្បត្តិដើម្បីអាចចូលរួមបេញថ្លៃ ឬ បុរេលក្ខណៈសម្បត្តិ</u>

អ្នកទទួលការដែលបានចុះបញ្ជីត្រឹមត្រូវ នៅនាយកដ្ឋានលទ្ធកម្មសាធារណៈ នឹងត្រូវចាត់ទុកថាមានសមត្ថភាពដើម្បីធ្វើការពិចារណាអោយចូលរួមដេញថ្លៃបាន ឬ បុរេលក្ខណៈសម្បត្តិក្នុងកិច្ចសន្យាណាមួយដោយផ្អែកទៅតាមកំរិតប្រភេទ និង ចំណាត់ថ្នាក់ ដូចមានចែងក្នុងវិញ្ញាបនប័ត្រចុះបញ្ជីរបស់អ្នកទទួលការនោះ ។

## ៤- **លក្ខខណ្ឌ សំរាប់ចុះបញ្ជី**

ក- <u>កំណត់ត្រាប្រវត្តិការងារ</u>

ជាទូទៅអ្នកដាក់ពាក្យសុំចង់បានបំពេញការងារវិស្វកម្ម ឬ ការងារសាងសង់ប្រហាក់ប្រហែលទៅតាមប្រភេទ និង ថ្នាក់ដែលគេសុំអោយធ្វើការចាត់ថ្នាក់ និង ចុះបញ្ជី ។

ជាគោលការណ៍តំលៃសរុបនៃកិច្ចសន្យា ឬ កិច្ចសន្យាបន្តដែលអ្នកដាក់ពាក្យសុំបានបំពេញក្នុងរយៈពេលបីឆ្នាំមុននេះយ៉ាងហោចណាស់ក៏ត្រូវស្មើនឹង តំលៃអតិបរមារបស់ប្រភេទអ្នកទទួលការនោះសំរាប់ ប្រភេទតូច និង ប្រភេទមធ្យម និង យ៉ាងហោចណាស់មានតំលៃស្មើនឹង ១.២៥០ លានរៀល សំរាប់ប្រភេទធំ ។

បើពុំដូច្នោះទេក្នុងរយៈពេលបីឆ្នាំមុន អ្នកដាក់ពាក្យសុំធ្លាប់បានបំពេញដោយជោគជ័យយ៉ាងហោចណាស់មួយគំរោង ក្នុងចំណាត់ថ្នាក់ ដែលមានតំលៃ មិនតិចជាង ៥០៎ នៃសមត្ថភាពដេញថ្លៃ (តំលៃសរុបនៃគំរោងការរយៈពេលបីឆ្នាំ)របស់ប្រភេទដូចមានតារាងបញ្ជាក់ខាងក្រោម :

( តួលេខគិតជាលានរៀល )

| ប្រភេទ | កំណត់ត្រាប្រវត្តិការងារ | |
|---|---|---|
| | សំរាប់ការងារសាងសង់ | |
| | តំលៃសរុបនៃគំរោងការ រយៈពេល៣ឆ្នាំ | ឬតំលៃនៃគំរោងការ ដែលធំបំផុត |
| ប្រភេទតូច | ១៥០ ដល់ ក្រោម ៥០០ | យ៉ាងហោច ៧៥ |
| ប្រភេទមធ្យម | យ៉ាងហោច ៥០០ | យ៉ាងហោច ២៥០ |
| ប្រភេទធំ | យ៉ាងហោច ១.២៥០ | យ៉ាងហោច ៦២៥ |

បន្ថែមទៅលើលក្ខខណ្ឌ ស្ដីពីតំលៃគំរោងការសរុបខាងលើ អ្នកដាក់ពាក្យសុំ ត្រូវធ្វើការ

អោយបានល្អប្រសើរជាហូរហែរបន្តបន្ទាប់ ។

ចំពោះអ្នកដែលមានប្រវត្តិការងារមិនល្អ ឬ មិនទៀងទាត់ គឺមិនអាចអោយចុះឈ្មោះក្នុងបញ្ជីបានឡើយ ។

ខ- **សមត្ថភាពហិរញ្ញវត្ថុ**

អ្នកដាក់ពាក្យសុំត្រូវបំពេញអោយបាន នូវល័ក្ខខ័ណ្ឌ របស់នាយកដ្ឋានលទ្ធកម្មសាធារណៈ ពោលគឺ ត្រូវមានធនធានគ្រប់គ្រាន់ ដើម្បីឆ្លើយតបទៅនឹងតំរូវការហិរញ្ញវត្ថុ ដែលបានកំណត់ហើយចាំបាច់ត្រូវផ្តល់មកជាមួយនឹងពាក្យសុំនូវសេចក្តីប្រកាសស្តីពីស្ថានភាពហិរញ្ញវត្ថុ ដ៏សមស្របរបស់ខ្លួន ( ដូចជារបាយការណ៍ប្រចាំឆ្នាំរបស់ក្រុមហ៊ុន ) ដែលបានបញ្ជាក់យ៉ាងច្បាស់ពីស្ថានភាពហិរញ្ញវត្ថុរបស់អ្នកដាក់ពាក្យសុំនៃឆ្នាំ កន្លងមក ។

គ- **ធនធានបុគ្គលិក**

អ្នកដាក់ពាក្យសុំត្រូវបំពេញអោយបាន នូវល័ក្ខខ័ណ្ឌ របស់នាយកដ្ឋានលទ្ធកម្មសាធារណៈ ពោលគឺត្រូវមានបុគ្គលិកចាំបាច់ដែលធ្វើការពេញម៉ោងក្នុងព្រះរាជាណាចក្រកម្ពុជាដើម្បីអនុវត្តការងារអោយបានសមស្របទៅនឹងឈ្មោះ ប្រភេទ ក្នុងចំណាត់ថ្នាក់ ដែលបានស្នើសុំ ។

លិខិតបញ្ជាក់ជំនាញរបស់បុគ្គលិក ក៏ដូចជាជំនាញបច្ចេកទេស ឯកទេស និង រយៈពេលនៃ បទពិសោធន៍ក្នុងការបំពេញការងាររបស់បុគ្គលិកនិមួយៗ ត្រូវតែភ្ជាប់មកជាមួយពាក្យសុំ ។

## ៥-**តារាងថ្លៃឈ្នួល**

ក- **ថ្លៃឈ្នួលលើដំណើការ**

រាល់ការសុំ ទោះជាការចុះបញ្ជីថ្មី ការសុំបន្ត បង្កើនឋានៈប្រភេទ ឬ ការបន្ថែមចំណាត់ថ្នាក់ ត្រូវតែដាក់ពាក្យសុំ " តាមគំរូដូចមានចែងក្នុងឧបសម្ព័ន្ធ២ " និង ភ្ជាប់មកជាមួយនូវ មូលប្បទានប័ត្រដែលមានទឹកប្រាក់ ស្មើនិងតំលៃនៃការស្នើសុំដែលចាត់ទុកជាថ្លៃឈ្នួលលើដំណើរការពិនិត្យ ។

ខ- **ថ្លៃឈ្នួលសុំចុះបញ្ជីលើកដំបូង**

អ្នកទទួលការ ដែលបានទទួលវិញ្ញាបនប័ត្របញ្ជាក់ ពីការចុះបញ្ជីលើកដំបូង ត្រូវតែបង់ថ្លៃឈ្នួលតាមប្រភេទរបស់ខ្លួនដូចខាងក្រោម :

| ប្រភេទ | ថ្លៃឈ្នួលតាមឈ្មោះប្រភេទក្នុងចំណាត់ថ្នាក់នីមួយៗ |
|---|---|
| ប្រភេទតូច | ១០០.០០០ រៀល |
| ប្រភេទមធ្យម | ២០០.០០០ រៀល |
| ប្រភេទធំ | ៣០០.០០០ រៀល |

គ- ថ្លៃឈ្នួលសុំចុះបញ្ជីបន្ត

អ្នកទទួលការ ដែលសុំចុះបញ្ជីបន្តជាថ្មីឡើងវិញ ត្រូវបង់ថ្លៃលើការសុំនោះ សមស្រប ទៅតាមប្រភេទរបស់ខ្លួន ដូចខាងក្រោម :

| ប្រភេទ | ថ្លៃឈ្នួលតាមឈ្មោះប្រភេទក្នុងចំណាត់ថ្នាក់នីមួយៗ |
| --- | --- |
| ប្រភេទតូច | ៨០.០០០ រៀល |
| ប្រភេទមធ្យម | ១៤០.០០០ រៀល |
| ប្រភេទធំ | ២០០.០០០ រៀល |

ឃ - ថ្លៃឈ្នួលសុំតំឡើងឋានៈប្រភេទ

អ្នកទទួលការដែលសុំតំឡើងឋានៈប្រភេទ ត្រូវបង់ថ្លៃឈ្នួលសុំតំឡើងឋានៈប្រភេទ សមស្របទៅតាមប្រភេទរបស់ខ្លួន ប្រសិន បើមានការអនុម័តយល់ព្រមជាផ្លូវការដូចខាងក្រោមនេះ :

| ប្រភេទ | តំឡើងទៅ | ថ្លៃឈ្នួលសំរាប់ឈ្មោះប្រភេទក្នុងចំណាត់ថ្នាក់និមួយៗ |
| --- | --- | --- |
| ប្រភេទតូច | ប្រភេទមធ្យម | ១៥០.០០០ រៀល |
| ប្រភេទមធ្យម | ប្រភេទធំ | ២៥០.០០០ រៀល |

ង - ថ្លៃឈ្នួលបន្ថែមឈ្មោះចំណាត់ថ្នាក់

អ្នកទទួលការ ដែលសុំបន្ថែមឈ្មោះចំណាត់ថ្នាក់ ត្រូវបង់ ថ្លៃចំណាត់ថ្នាក់ទៅតាម ប្រភេទរបស់ខ្លួន ដូចតទៅ :

| ប្រភេទ | ថ្លៃឈ្នួលសំរាប់បន្ថែមឈ្មោះចំណាត់ថ្នាក់និមួយៗ |
| --- | --- |
| ប្រភេទតូច | ៨០.០០០ រៀល |
| ប្រភេទមធ្យម | ១៦០.០០០ រៀល |
| ប្រភេទធំ | ២៤០.០០០ រៀល |

## ៦-ធាបៀបទូទាត់

រាល់ថ្លៃឈ្នួលទាំងអស់ត្រូវតែទូទាត់ជាមូលប្បទានប័ត្រផ្ទួត ឬ រូបិយាណត្តិរបស់ធនាគារ អោយមកនាយកដ្ឋានលទ្ធកម្មសាធារណៈដោយផ្ទាល់ ។ ថ្លៃឈ្នួលដែលបានបង់រួចមិនអាចដកវិញបានឡើយ ។

**៧-ការជូនដំណឹងអោយបានទាន់ពេលនូវចំណុចពិសេសណាមួយរបស់អ្នកទទួលការ**

អ្នកទទួលការ ដែលបានចុះបញ្ជីរួចហើយ ចាំបាច់ត្រូវផ្តល់ពត៌មាន ដល់នាយកដ្ឋានលទ្ធកម្មសាធារណៈភ្លាម រាល់ការកែប្រែស្ថានភាពគ្រប់គ្រង អាស័យដ្ឋាន ឬចំណុចពិសេស ដែលមានការពាក់ព័ន្ធណាមួយរបស់ខ្លួន ។

**៨- លិខិតយោង :**

ក្នុងរយៈពេលដំណើរការដាក់ពាក្យសុំ នាយកដ្ឋានលទ្ធកម្មសាធារណៈ អាចសួរពត៌មានទៅធនាគាររបស់អ្នកសុំ ឬក៏អតិថិជន ឬ អ្នកឯកទេសដែលធ្លាប់បានគ្រប់គ្រងការងារសាងសង់ របស់អ្នកដាក់ពាក្យសុំពីមុនមក ។

អ្នកដាក់ពាក្យសុំ មានកាតព្វកិច្ចត្រូវអនុញ្ញាតិអោយ នាយកដ្ឋានលទ្ធកម្មសាធារណៈ ធ្វើការសាកសួររាល់ពត៌មាន ដែលយល់ថាជាការចាំបាច់ ។

ប្រសិនបើធនាគារ ឬ អតិថិជនរបស់អ្នកដាក់ពាក្យសុំ យកថ្លៃសេវាចំពោះការសាកសួរពត៌មាននោះ ៗ អ្នកដាក់ពាក្យសុំត្រូវតែចេញរាល់សោហ៊ុយ លើសេវានោះ ។

**៩-វិញ្ញាបនប័ត្របញ្ជាក់ការចុះបញ្ជី :**

លិខិតបញ្ជាក់ការចុះបញ្ជី គឺជាកម្មសិទ្ធិ របស់នាយកដ្ឋានលទ្ធកម្មសាធារណៈ ហើយត្រូវតែប្រគល់មកអោយ នាយកដ្ឋានលទ្ធកម្មសាធារណៈវិញ នៅពេលអ្នកទទួលការ ធ្វើខុសនឹងកិច្ចសន្យា ឬនៅពេលដែលការចុះបញ្ជីរបស់អ្នកទទួលការ អស់សុពលភាព ឬ ត្រូវដកហូតវិញដោយហេតុផលណាមួយ ។

ភ្ជាប់ជាមួយនិងគោលការណែនាំមានឧបសម្ព័ន្ធទី១ និង ឧបសម្ព័ន្ធទី២ ។

រាជធានីភ្នំពេញ. ថ្ងៃទី ១៤ ខែវិច្ឆិកា ឆ្នាំ១៩៩៥

នាយកដ្ឋានលទ្ធកម្មសាធារណៈ

ជ. ប្រធាន

គាយ - ទុជ

លេខ ៖ ២០២៩សហវ

បានឃើញ និង ឯកភាព

រាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥

ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

គាត ឈន់

# ចំណាត់ថ្នាក់ នៃគំរោង ហេដ្ឋារចនាសម្ព័ន្ធ

++++++++

| លេខសំគាល់ | ឈ្មោះថ្នាក់ | បរិយាយ |
| --- | --- | --- |
| W1 | **ផ្លូវថ្នល់ និង ស្ពាន** | - ការសាងសង់ផ្លូវ ស្ពាន ( ក្រាលដីស្រទាប់ក្រោម លាប ឬបិទ ក្រាលថ្មអោយរឹង ឬ អោយរស់) ស្ពានថ្ម ឬ ដែក លូទឹក ចិញ្ចើមថ្នល់ និង ផ្លូវថ្មើរជើង ផ្លូវសំរាប់ដើរឆ្លងកាត់។<br>- ការស្តារ ការសង់អោយដូចដើម ការកែលំអជាយផ្លូវ សំរួលចំណោតផ្លូវ កែសំរួលប្រព័ន្ធបង្ហូរទឹក ចាក់គ្រួសល្អិត ឬចាក់ក្រាលឈើកំរាលផ្លូវថ្នល់ សង់ឡើងវិញនូវ កន្លែងផ្លូវថ្នល់ដែលខូច ជួសជុល ឬ សង់ឡើងវិញនូវស្ពានដែលបែកបាក់ ឬ ខ្ទេចខ្ទី។ |
| W2 | **ព្រលានយន្តហោះ** | - ការសាងសង់ផ្លូវយន្តហោះ បង្ហូរទឹក ក្រាលផ្លូវយន្តហោះ សំណង់ទីសំចត រោងយន្តហោះ និង ឃ្លាំង ។ |
| W3 | **សំណង់អគារ** | - សំណង់ ឈើ ថ្ម ដែក លាបពណ៌សំណង់គ្រប់ប្រភេទ ។<br>- ការស្តារនិងសង់ឡើងវិញនូវសំណង់ដែលខូចខាត ឬបាក់បែក ខ្ទេចខ្ទី ។ |
| W4 | **ប្រព័ន្ធធារាសាស្រ្ត ប្រព័ន្ធបង្ហូរទឹកនិងប្រព័ន្ធ គ្រប់គ្រងទឹកជំនន់** | - ការសង់ និង ស្តារនូវប្រព័ន្ធស្រោចស្រព និង ប្រព័ន្ធបង្ហូរទឹក បណ្តាញផ្លូវ ក្នុងប្រព័ន្ធស្រោចស្រព ការជីកស្រះ ការរានដីដែលគេបោះបង់ចោល ។ |
| W5 | **ផ្លូវរថភ្លើង** | - ការសង់ផ្លូវដែក ស្ពាន លូទឹកកាត់ក្រោមផ្លូវ<br>- ការស្តារសំណង់ទាំងឡាយដូចជា ពង្រឹងនិងជួសជុលផ្លូវដែក ព្រមទាំងស្ពានផ្លូវរថភ្លើង ។ |
| W6 | **កំពង់ផែ** | - ការសង់ប្រព័ន្ធសំណង់នៅជាប់ និង ឈើសមុទ្រ ឬ ទន្លេ ដូចជាសំណង់របាំងផែ ផែ របងផែ ចាក់គ្រឹះផែ ពោងផែ ឃ្លាំងផ្ទុកទំនិញ ។<br>- ការបូមដី ។ |